ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

វិទ្យាស្ថានស្តង់ដារកម្ពុជា
Institute of Standards of Cambodia
លេខៈ ៤១៦/១៤ វិលក.សដណ

រាជធានីភ្នំពេញ, ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៤

# សេចក្តីជូនដំណឹង
# ស្តីពី
# ការផ្សព្វផ្សាយសេចក្តីព្រាងស្តង់ដារកម្ពុជាសម្រាប់
# សរសៃដែកសម្រាប់ការសាងសង់ និង
# សេចក្តីព្រាងស្តង់ដារកម្ពុជាសម្រាប់បំពង់ប្លាស្ទិច (PVC)

## ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៣ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីស្តង់ដារកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងសេចក្តីសម្រេចលេខ ១០៧ MIH/2014 ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤ ស្តីពីនីតិវិធីនៃដំណើរការអភិវឌ្ឍស្តង់ដារកម្ពុជា

សូមជម្រាបជូនដំណឹងដល់ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម សេវាកម្ម និងសាធារណជនដែលមានការពាក់ព័ន្ធជ្រាបថាៈ វិទ្យាស្ថានសូមធ្វើការផ្សព្វផ្សាយអំពី "សេចក្តីព្រាងស្តង់ដារកម្ពុជាសម្រាប់សរសៃដែកសម្រាប់ការសាងសង់ និងសេចក្តីព្រាងស្តង់ដារកម្ពុជាសម្រាប់បំពង់ប្លាស្ទិច (PVC)" ក្នុងគោលបំណងផ្តល់ឱកាសដល់ក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម និងសាធារណជនដែលមានការពាក់ព័ន្ធ ឬចំណាប់អារម្មណ៍ទៅនឹងស្តង់ដារព្រាងខាងលើនេះ អាចធ្វើការពិនិត្យគ្រប់ចំណុចនៃសេចក្តីព្រាងស្តង់ដារទាំងនេះនៅវិទ្យាស្ថានស្តង់ដារកម្ពុជា ឬនៅគ្រប់មន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានី-ខេត្ត នៅរៀងរាល់ម៉ោងធ្វើការ ឬតាមគេហទំព័រ www.isc.gov.kh ដើម្បីផ្តល់មតិ ឬធ្វើការតវ៉ាជំទាស់មក វិទ្យាស្ថានស្តង់ដារកម្ពុជា ជាលាយល័ក្ខណ៍អក្សរដោយត្រូវបញ្ជាក់ និងបង្ហាញពីមូលហេតុនៃការផ្តល់មតិ ឬការតវ៉ាជំទាស់ទៅនឹងស្តង់ដារព្រាងនេះឱ្យបានច្បាស់លាស់នៅក្នុង រយៈពេលសាមសិប (៣០) ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីជូនដំណឹងនេះតទៅ។

ស្តង់ដារព្រាងខាងលើនឹងត្រូវដាក់ឆ្លងកិច្ចប្រជុំក្រុមប្រឹក្សាស្តង់ដារជាតិដើម្បីអនុម័ត និងប្រកាសឱ្យទៅជាស្តង់ដារកម្ពុជាផ្លូវការក្រោយពីៈ

ក/- រយៈពេលសាមសិបថ្ងៃ ដោយគិតចាប់ពីថ្ងៃជូនដំណឹងនេះតទៅ ក្នុងករណីគ្មានការផ្តល់មតិ ឬការតវ៉ាជំទាស់

ខ/- បានធ្វើការពិនិត្យ និងដោះស្រាយរួចរាល់នូវរាល់ការផ្តល់មតិឬការតវ៉ាជំទាស់។

វិទ្យាស្ថានស្តង់ដារកម្ពុជា សង្ឃឹមថាក្រុមហ៊ុន រោងចក្រ សហគ្រាស សិប្បកម្ម សេវាកម្ម និងសាធារណជនដែលមានការពាក់ព័ន្ធ ឬចំណាប់អារម្មណ៍ទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងខាងលើនេះ ដោយស្មោះស្ម័គ្រជាទីបំផុត៕

**ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា**

**ចាន់ បូរិន្ទ**

**<u>កន្លែងទទួល</u>** ៖

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
  "ដើម្បីគោរពជូនជ្រាប"
- ក្រសួងមហាផ្ទៃ
- ក្រសួងយុត្តិធម៌
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងរ៉ែ និងថាមពល
- ក្រសួងព័ត៌មាន
- ក្រសួងសុខាភិបាល
- ក្រសួងបរិស្ថាន
- ក្រសួងទេសចរណ៍
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងអប់រំ យុវជន និងកីឡា
- គ្រប់សាកលវិទ្យាល័យ-មហាវិទ្យាល័យពាក់ព័ន្ធចំណុះក្រសួងអប់រំ យុវជន និងកីឡា
- គ្រប់សាលារាជធានី-ខេត្ត
- គ្រប់មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី-ខេត្ត
  "ដើម្បីផ្សព្វផ្សាយ"
- ឯកសារ - កាលប្បវត្តិ